# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៩ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការបំពេញបន្ថែម មាត្រា៥ ជំពូកទី២ មាត្រា៣៧ ជំពូកទី៨ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ២៩អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្ដីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពី ឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៣០៤ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលមាត្រា៣២ មាត្រា៣៦ និងមាត្រា៤០ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ខែកុម្ភៈ ឆ្នាំ២០១៧ និងមាត្រា១៣ថ្មី នៃអនុក្រឹត្យលេខ ២២១ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រាមួយ .~**

ត្រូវបានបំពេញបន្ថែម មាត្រា៥ ជំពូកទី២ មាត្រា៣៧ ជំពូកទី៨ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ ត្រូវបាន រៀបចំដូចខាងក្រោម៖

**មាត្រា៥ .~ ថ្មី**

ត្រូវបានរៀបចំបន្ថែមឯកសណ្ឋានលេខ៣ដៃវែង សម្រាប់កងទ័ពជើងគោក កងទ័ពជើងទឹក កងទ័ព ជើងអាកាស និងកងរាជអាវុធហត្ថ ដែលមានរូបភាព និងគំរូដូចខាងក្រោម៖

- ខោ អាវ និងមួកកាស្កេតពណ៌តាមប្រភេទទ័ព

- អាវដៃវែង កឱប ខាងក្រោយមានផែក និងប៉ានចង្កេះនៅខាងក្រោយ ផ្នែកខាងមុខមានហោប៉ៅបួន ខាងលើ២ ដេរប៉ះ ចាប់ផ្នត់មួយចំកណ្តាល មានគម្របរាងស្លឹកពោធិ៍ និងខាងក្រោម២ ដេរបង្កប់ មានគម្រប រាងស្លឹកពោធិ៍ មានប៊ូលស្នាដាក់ឡេវជ័រ មានអង្កត់ផ្ចិត១៤ម.ម។ ចាប់ពីកអាវមកដល់ក្រោមមានឡេវចំនួន៦គ្រាប់ មានរូបព្រះសង្ការពណ៌មាស ធ្វើពីលោហធាតុ មានអង្កត់ផ្ចិត២០ម.ម ឡេវហោប៉ៅលើ ២គ្រាប់មានអង្កត់ផ្ចិត ១៥ម.ម និងឡេវហោប៉ៅក្រោម ២គ្រាប់មានអង្កត់ផ្ចិត ១៨ម.ម មានរូបព្រះសង្ការពណ៌មាស ធ្វើពីលោហធាតុ

- ដៃអាវវែងកាត់រាងបំពង់ ដេរប៉ាននៅចុងដៃរាងជាវង្វង់ ប្រវែងពីចុងដៃអាវចំនួន៨០ម.ម និងមានដាក់ ឡេវបញ្ឆោត ៤គ្រាប់ រូបព្រះសង្ការទំហំ ១៥ម.ម ធ្វើពីលោហធាតុ ពណ៌មាស រៀបបញ្ឈរតាមដៃអាវ

- ខោជើងវែងកាត់ដូចខោឯកសណ្ឋានលេខ៤។

ចំពោះនារីអាវមានគំរូដូចបុរស និងសំពត់ហ្ស៊ីបពណ៌តាមប្រភេទទ័ពសម្រុងក្រោមក្បាលជង្គង់។

**ឯកសណ្ឋានលេខ៣ដៃវែង សម្រាប់កងទ័ពជើងគោក កងទ័ពជើងទឹក កងទ័ពជើងអាកាស និងកងរាជ អាវុធហត្ថ មានគំរូដូចក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។**

**មាត្រា៣៧ .~ ថ្មី**

ត្រូវបានបំពេញបន្ថែម ទង់កងកិត្តិយសសម្រាប់បដិសណ្ឋារកិច្ច ព្រះមហាក្សត្រ ប្រធានាធិបតី ប្រមុខរដ្ឋ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី ជាតិ-អន្តរជាតិមានរូបភាព និងខ្នាតដូចខាងក្រោម៖

**+ រូបភាព និងខ្នាត**

យកគំរូទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា រាងចតុកោណកែង បណ្តោយប្រវែង ១៧៨ស.ម និងទទឹង ១៣៥ស.ម។ ដងទង់ប្រវែង២៨៥ស.ម ធ្វើពីលោហធាតុ ឬឈើ ពណ៌ស មានទំហំអង្កត់ផ្ចិត៤ស.ម។ ក្បាលដង ទង់ខាងលើឆ្លាក់រូបព្រហ្មមុខបួន កម្ពស់២៥ស.ម ធ្វើពីលោហធាតុពណ៌មាស។ នៅក្បាលដងទង់មានរំយោល ចងក្បាលដងទង់ពីរ ពណ៌មាស មួយប្រវែង៤០ស.ម និងមួយទៀតប្រវែង៥០ស.ម។ នៅជាយទង់មាន រំយោល ពណ៌មាសព័ទ្ធជុំវិញចំនួនបីជ្រុង រំយោលមានប្រវែង៣ស.ម។

**+ ការប្រើប្រាស់**

ទង់នេះត្រូវប្រើប្រាស់សម្រាប់ពិធីបដិសណ្ឋារកិច្ច និងពិធីវន្ទនៈកិច្ចនានាថ្វាយ-ជូន ព្រះមហាក្សត្រ ប្រធានាធិបតី ប្រមុខរដ្ឋ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី ជាតិ-អន្តរជាតិ។

**រូបភាពទង់មានគំរូដូចក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។**

**មាត្រាពីរ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រី** សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាពីរ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...៦៩ អនក្រ.បក.......ចុះថ្ងៃទី...១២.......ខែ...ឧសភា.....ឆ្នាំ២០២៥
ស្តីពី ការកែសម្រួល បំពេញបន្ថែម មាត្រា៥ ជំពូកទី២ មាត្រា៣៧ ជំពូកទី៨ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

១. ឯកសណ្ឋានលេខ៣ ដៃវែង

កងទ័ពជើងគោក



កងទ័ពជើងទឹក



កងទ័ពជើងអាកាស



កងរាជអាវុធហត្ថ



២. ទង់កងកិត្តិយសសម្រាប់បដិសណ្ឋារកិច្ច ព្រះមហាក្សត្រ ប្រធានាធិបតី ប្រមុខរដ្ឋ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី ជាតិ-អន្តរជាតិ

